ISSN 1810-6358

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**Cambodia Development Resource Institute**

# របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា

# Flash Report on the Cambodian Economy

កុម្ភៈ ២០០៦ / February 2006

កញ្ញា អ៊ុច ច័ន្ទតារានី / **Ms. Ouch Chandarany**

លោកស្រី ប៉ុន ដូរីណា / **Ms. Pon Dorina**

លោក ហ៊ីង វុទ្ធា / **Mr. Hing Vutha**

លោក ភឹម រុនស៊ីណារិទ្ធិ / **Mr. Phim Runsinarith**

បកប្រែដោយ: **យូ សិទ្ធីរិទ្ធ**

## ភ្នំពេញ កម្ពុជា

## Phnom Penh, Cambodia

**TO SUBSCRIBE, PLEASE CONTACT:**

*Office Address:* #56, Street 315, Tuol Kork, Phnom Penh, Cambodia, *Postal Address:* CDRI, PO Box 622 Phnom Penh, Cambodia
*Tel:* (855-23) 881-384/881-701/881-916/883-603 *Tel/fax:* (855-23) 880-734 *E-mail:* pubs@cdri.forum.org.kh *Website:* http://www.cdri.org.kh

# សកម្មភាពសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា

# Main Economic Activities of Cambodia

នៅត្រីមាសទី៣ ២០០៥ វិនិយោគឯកជនក្នុងវិស័យសេវាកម្ម ដែលបានទទួលការអនុមតិមាន ៤៤,១លានដុល្លារ រឺ ៤៧,០%ច្រើនជាងត្រីមាសមុន និង ៧ដងច្រើនជាងត្រីមាសដូចគ្នាឆ្នាំ២០០៤ ។ ក្នុងនេះ ៣៣,៦លានដុល្លារជាវិនិយោគខាងកន្លែងទេសចរណ៍ (ជាអាទិ៍ សណ្ឋាគារ, ហាងលក់ទំនិញ, ភូមិលំហែ, និងក្លិបវាយកូនគោល) ហើយ ១០,៥លានដុល្លារជាវិនិយោគពង្រីកសេវាកម្មខាងថាមពល ។

Private investment approvals in services amounted to about $44.1 million in the third quarter of 2005, 47.0 percent more than in the preceding quarter and about seven times more than in the same quarter of 2004. Of total investment in the sector in the third quarter, about $33.6 million was invested in a tourist resort (including a hotel, superstore, holiday village and golf club) by Cambodian (51 percent) and Chinese (49 percent) investors. The remaining $10.5 million went into expansion of energy services.

**Private Investments in Service Sector Approved by CDC** (US$ million)




*Note: Latest data available are for September 2005. Including expansion project approvals.*
Source: Council for the Development of Cambodia

នៅខែវិច្ឆិកា ២០០៥ មានភ្ញៀវបរទេស ១៣៨.២៩៣នាក់ មកដល់កម្ពុជា តាមគ្រប់មធ្យោបាយដឹកជញ្ជូន រឺ ១៨.៨%ច្រើនជាងខែមុន និង ២៦.៨% ច្រើនជាងខែវិច្ឆិកា ២០០៤ ។ ក្នុងនេះ ភ្ញៀវមកដល់តាមយន្តហោះកើន ២៧% ដល់ ៩១.៣៤៧នាក់, តាមផ្លូវគោក និងផ្លូវទឹកកើន ៥.៦% ដល់ ៤៦.៩៤៦នាក់ ។

The number of foreign visitor arrivals in Cambodia by all modes of transportation in November was 138,293 persons, 18.8 percent more than in October. Arrivals by air increased by 27 percent to 91,347 persons, and land and boat arrivals increased by 5.6 percent to 46,946 persons. Compared to November 2004, total foreign visitors were up by 26.8 percent.

**Foreign Visitor Arrivals in Cambodia**
(thousand persons)




*Note: Latest data available are for November 2005.*
Source: Ministry of Tourism

តំលៃគំរោងសាងសង់ដែលបានអនុម័តនៅភ្នំពេញ កើនដល់ ៣៦,០លានដុល្លារនៅខែវិច្ឆិកា ២០០៥ ធៀបនឹង ១៤,៨លានដុល្លារនៅខែតុលា។ ក្រោយបានថយចុះនៅខែតុលា តំលៃគំរោងសាងសង់ផ្ទះល្វែងកើនដល់ ២៦,៦លានដុល្លារ ធៀបនឹង ៤,២លានដុល្លារនៅខែមុន ។ ការសាងសង់ភូមិគ្រឹះ និងផ្ទះ ក៏កើនដល់ ២,៤លានដុល្លារ ពីកំរិត ០,៥លានដុល្លារ ប៉ុន្តែ សំណង់ឯទៀតបានថយចុះពី ១០,១លានដុល្លារ ដល់ ៧,០លានដុល្លារ។

Construction project approvals in November 2005 were valued at $36.0 million, up from $14.8 million in October. After declining in October, the value of flat construction approvals rose to $26.6 million, up from $4.2 million. Villa and house construction also increased, to $2.4 million from $0.5 million, while other construction activity fell from $10.1 million to $7.0 million. Compared to November 2004, the total value of construction project approvals slightly more than doubled.

**Value of Construction Project Approvals in Phnom Penh** (US$ million)




*Note: Latest data available are for November 2005.*
Source: Department of Cadastre and Geography, Phnom Penh municipality

# អត្រាការប្រាក់ និង ថ្លៃទំនិញ

# Price and Interest Rate Developments

ថ្លៃលក់ជាមធ្យមរបស់សាំង និងម៉ាស៊ូតនៅភ្នំពេញរបស់ ៦ក្រុមហ៊ុនធំៗ បន្តធ្លាក់ចុះ ។ នៅខែមករា សាំងលក់ថ្លៃ ៣.៦៩៧,៦រៀល/លីត្រ រឺ ០,៤% ទាបជាងខែមុន ហើយម៉ាស៊ូតចុះថ្លៃ ០,៧% ដល់២.៨៦០,៥រៀល/លីត្រ ។ ប៉ុន្តែ ទាំងសាំង និងម៉ាស៊ូត ហាក់ដូចឡើងថ្លៃវិញក្នុង ២-៣ថ្ងៃមុនដាច់ខែ។

The average market prices of gasoline and diesel in Phnom Penh from six companies continued to drop. In January, gasoline was 3,697.6 riels/litre, 0.4 percent lower than in the preceding month. Diesel declined by 0.7 percent to 2,860.5 riels/litre. However, both gasoline and diesel prices appeared to rise during a few days at the end of the month.

### Price of Gasoline and Diesel Oil in Phnom Penh

(Riels per litre)




Sources: CDRI and National Institute of Statistics

នៅខែធ្នូ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញបន្តធ្លាក់ចុះ ០,២៤% ក្រោយបានចុះអស់ ០,១%នៅខែវិច្ឆិកា ។ សន្ទស្សន៍ថ្លៃសំខាន់ៗពីរទៀតគឺ ម្ហូបអាហារ និង ដឹកជញ្ជូន/ទូរគមនាគមន៍ថយចុះ ០,៤៧% និង០,៥៤% ។ ថ្លៃទំនិញប្រើ ប្រាស់សរុបបានកើនឡើង ៦,៦%នៅខែធ្នូ បើធៀបនឹងខែដូចគ្នាឆ្នាំមុន ។

The consumer price index in Phnom Penh continued downward in December, falling by 0.24 percent in December, after a 0.1 percent decrease in November. The two major price indices, food and transportation and communication, declined by 0.47 percent and by 0.54 percent, respectively. Overall consumer prices in December were up 6.6 percent from the same month last year.

### Consumer Price Index

(July–December 2000=100)




*Note: Latest data available are for December 2005.*
Source: National Institute of Statistics

អង្កេត វិបសអ លើពលករងាយរងគ្រោះនៅភ្នំពេញ បង្ហាញថា ចំនូលប្រចាំថ្ងៃពិតរបស់ក្រុម អ្នកធាក់ស៊ីក្លូ អ្នករត់ម៉ូតូឌុប និងកម្មករសំនង់គ្មានជំនាញបានកើនឡើងនៅខែវិច្ឆិកា ២០០៥ បើធៀបនឹងខែវិច្ឆិកា ២០០៤ ។ ចំនូលរបស់អ្នកធាក់ស៊ីក្លូ កើន ៤៥,០% ដល់ ៨.២៣០រៀល, អ្នករត់ម៉ូតូឌុបកើន ១២,៥% ដល់ ៩.៧៧៥រៀល និង កម្មករសំនង់គ្មានជំនាញកើន ១២,៦% ដល់ ៦.៦៩០រៀល ។

The CDRI survey on vulnerable workers in Phnom Penh revealed that real daily earnings of three groups of vulnerable workers—cyclo drivers, motorcycle taxi drivers and unskilled construction workers—increased in November 2005, compared to the same month of 2004. Real daily earning of cyclo drivers rose markedly, by 45.0 percent to about 8,230 riels. Motorcycle taxi drivers' real daily earnings rose 12.5 percent to 9,775 riels. Similarly, unskilled construction workers earned 6,690 riels per day, up 12.6 percent or about 750 riels.

### Real Daily Average Earnings of Vulnerable Workers in Phnom Penh

(at November 2000 prices)




**Revised*
Source: CDRI and National Bank of Cambodia

# ស្ថានភាពអត្រាប្តូរប្រាក់ និង រូបិយវត្ថុ
# Exchange Rate and Monetary Developments

នៅខែមករា អត្រាប្តូរប្រាក់ជាមធ្យមនៅលើទីផ្សារ គឺប្រហែល ៤.១០០ រៀល/ដុល្លារ ដោយប្រាក់រៀលឡើងថ្លៃ ០,៩% ពីកំរិត ៤.១៣៨,៤ រៀល/ដុល្លារ នៅខែមុន ថ្វីបើមានការចេញផ្សាយក្រដាសប្រាក់ថ្មីទៀតក្តី ។ បើធៀបនឹងខែមករា ២០០៥ ប្រាក់រៀលបានចុះថ្លៃ ១,៥% ។

The average market exchange rate between the riel and the US dollar was around 4,100 riels/dollar in January. The riel appreciated about 0.9 percent from 4,138.4 riels/dollar in the previous month, although there were more new riels issued. Compared to January 2005, however, the riel has depreciated by 1.5 percent.

**Riels per US Dollar**




Sources: National Bank of Cambodia and CDRI

នៅខែមករា ប្រាក់រៀលបន្តឡើងថ្លៃ ទល់នឹងប្រាក់ដុងវៀតណាម ដោយប្តូរបានជាមធ្យម ២៥,៦រៀល/១០០ដុង (ឡើងថ្លៃ ១,២% ពីកំរិត ២៥,៩រៀល/១០០ដុង នៅខែមុន) ។ ប៉ុន្តែប្រាក់រៀលបានចុះថ្លៃទល់នឹងប្រាក់បាត (ក្រោយពីបានឡើងថ្លៃនៅខែធ្នូ) ដោយប្តូរបាន ១០២,៥រៀល/បាត (១០០,៦រៀល/បាត នៅខែមុន ) ។

In January, the riel continued to appreciate against the Vietnamese dong, trading at 25.6 riels per 100 dong, an appreciation of 1.2 percent from 25.9 riels in the preceding month. However, the riel depreciated against the baht in January, after gaining in December. The riel traded at 102.5 riels per bath, up from 100.6 riels per bath.

**Riels per Thai Baht and 100 Vietnamese Dong**




Source: CDRI

នៅខែវិច្ឆិកា រូបិយវត្ថុទូទៅកើន ១,៤% ដល់ ៥.០៣៣,៥ពាន់លានរៀល ក្រោយបានថយចុះនៅខែមុន ។ ក្នុងនេះចំណែកជារូបិយវត្ថុបរទេសកើនប្រហែល ២,១% ដល់ ៨៧៤,៨លានដុល្លារ រឺ ៣.៦៤៧,៩ពាន់លានរៀល ។ ប្រាក់រៀលនៅក្រៅធនាគារ កើន ០,៩% ដល់ ១.២៣៣,៨ពាន់លានរៀល រីឯប្រាក់រៀលផ្ញើនៅធនាគារថយចុះ ២,៥% ដល់ ១៥១,៨ពាន់លានរៀល ។

After decreasing in the preceding month, the money supply expanded by 1.4 percent to 5,033.5 billion riels in November. Of this, foreign currency deposits rose by about 2.1 percent to $874.8 million, or 3,647.9 billion riels. Riels circulating outside banks rose to 1,233.8 billion, a 0.9 percent increase, while riels in bank deposits declined by 2.5 percent to 151.8 billion.

**Liquidity of the Banking System**
(billion riels)




*Note: Latest data available are for November 2005.*
Source: National Bank of Cambodia

# ពាណិជ្ជកម្មក្រៅប្រទេស

# External Trade

នៅខែវិច្ឆិកា ២០០៥ ការនាំចេញកសិផលចំបង៧ (កៅស៊ូ, ត្រី, អង្ករ) បានថយចុះ បើធៀបនឹងខែដូចគ្នាឆ្នាំមុន ។ ការនាំចេញ កៅស៊ូថយចុះ ៤,៧% ដល់ ៤,១លានដុល្លារ, ត្រីថយចុះ ៧,១% ដល់ ២,៦លានដុល្លារ ហើយអង្ករថយចុះដល់សូន្យ ពីកំរិត ០,២លានដុល្លារ ។ ប៉ុន្តែការនាំចេញសំលៀកបំពាក់កើន ១៤,៨% ដល់ ១៧៣,០លានដុល្លារក្នុងកំឡុងពេលនេះ ហើយការនាំចេញសរុបកើន ១៨,៣% ដល់ ១៨៩,០លានដុល្លារ ។

Exports of major agricultural products (rubber, fish and rice) declined in November, compared to the same month of 2004. Rubber exports were down by 4.7 percent to $4.1 million, fish exports declined by 7.1 percent to $2.6 million, and rice exports fell to nil from $0.2 million. However, exports of garments rose by 14.8 percent to about $173.0 million during this period, while total exports increased by 18.3 percent to $189.0 million.

**Cambodia's Main Exports**
(US$ million)




*Note: Latest data available are for November 2005.*
Source: Customs and Excise Department

នៅខែវិច្ឆិកា ២០០៥ ការនាំចូលស៊ីម៉ង់ត៍កើនដល់ ១៣,៨ពាន់លានរៀល រឺកើន ៣០,២%ធៀបនឹងខែមុន និង ២២,១%ធៀបនឹងខែដូចគ្នាឆ្នាំ២០០៤។ ផ្ទុយទៅវិញ ការនាំចូលដែកចុះដល់ ៥ពាន់លានរៀល រឺចុះ ១៨%ធៀបនឹងខែតុលា និង ៤០,៥%ធៀបនឹងខែវិច្ឆិកា ២០០៤ ។ ដូចគ្នាដែរ ការនាំចូលបារីចុះដល់ ២៥,៤ពាន់លានរៀល រឺចុះ ៣៣,៣% ធៀបនឹងខែតុលា និងចុះ ២៨,៥%ធៀបនឹងខែវិច្ឆិកា ២០០៤ ។

Cement imports amounted to 13.8 billion riels in November, an increase of 30.2 percent from the preceding month and 22.1 percent from the same month of 2004. In contrast, steel imports declined to 5 billion riels, down by 18 percent from October and 40.5 percent from the November 2004. Likewise, imports of cigarettes were 25.4 billion riels, 33.3 percent less than in October and 28.5 percent less than the same month of 2004.

**Imports of Cigarettes and Construction Materials**
(billion riels)




*Note: Latest data available are for November 2005.*
*(Excluding public sector imports.)*
Source: Customs and Excise Department

នៅខែវិច្ឆិកា ការនាំចូលសាំង និងម៉ាស៊ូត មានចំនួន ៣៧,២ពាន់លានរៀល និង ១០,៨ពាន់លានរៀល រៀងគ្នា ។ បើធៀបនឹងខែមុន ការនាំចូលម៉ាស៊ូតកើនយ៉ាងខ្លាំងដល់ ៨៧,៤% ឯការនាំចូលសាំងធ្លាក់ចុះអស់ ៤០% ។ បើធៀបនឹងខែវិច្ឆិកា ២០០៤ ការម៉ាស៊ូតថយចុះ ០,៤% ឯការនាំចូលសាំងស្ទុះឡើង ២១,៧% ។

Imports of diesel oil and gasoline amounted to 37.2 billion riels and 10.8 billion riels respectively in November. Compared to the preceding month, diesel imports rose sharply, by 87.4 percent, while gasoline imports dropped by 40 percent. Compared to November 2004, diesel imports were down by 0.4 percent, while gasoline imports jumped by 21.7 percent.

**Imports of Petroleum Products**
(billion riels)




*Note: Latest data available are for November 2005.*
*(Excluding public sector imports.)*
Source: Customs and Excise Department

# ប្រភព និងការប្រើប្រាស់ជំនួយបរទេស

# Sources and Uses of Foreign Assistance

ខេត្តកំពង់ឆ្នាំងទទួលបានមូលនិធិរបស់ឃុំ/សង្កាត់ ២,៥៩ពាន់លានរៀល នៅឆ្នាំ២០០៥ រឺ ១៤,៦%ច្រើនជាងឆ្នាំ២០០៤ ។ ក្នុងនេះមូលនិធិសំរាប់អភិវឌ្ឍន៏មាន ១,៨១ពាន់លាន និងសំរាប់រដ្ឋបាល ០,៧៨ពាន់លាន ។ ខេត្តនេះមាន៨ស្រុក ហើយស្រុករលាប្អៀរបានច្រើនជាងគេគឺ ០,៥១ពាន់លាន ។

Kompong Chhnang province received 2.59 billion riels from the commune/sangkat fund in 2005, 14.6 percent more than in 2004. Funds for development activities were slightly below 1.81 billion riels, and for administration were 0.78 billion riels. The province has eight districts (69 communes). Ro Lea Peear district (13 communes) received nearly 0.51 billion riels, Baribour (11 communes) 0.37 billon riels, Kompong Tralach (10 communes) 0.42 billion riels, Samaki Meanchey (nine communes) 0.35 billion riels, Kompong Leaeng (nine communes) 0.30 billion riels, Tuek Phos (eight communes) 0.30 billion riels, Chol Kiri (five communes) 0.18 billion riels, and Kompong Chhnang (four communes) 0.16 billion riels.

**2005 Commune/Sangkat Fund Allocation to Kompong Chhnang Province**




Source: Seila Task Force (January 2005), Annual Work Plan and Budget 2005

ខេត្តពោធិសាត់ (នៅជាប់ខេត្តកំពង់ឆ្នាំង) ទទួលមូលនិធិរបស់ឃុំ/សង្កាត់បាន ២,០២ពាន់លានរៀលនៅឆ្នាំ២០០៥ រឺ ១៤,០%ច្រើនជាងឆ្នាំ២០០៤ ។ ក្នុងនេះមូលនិធិសំរាប់អភិវឌ្ឍន៏មាន ១,៣៨ពាន់លានរៀល និងសំរាប់រដ្ឋបាល ០,៦៤ពាន់លានរៀល ។

Pursat province, which is close to Kompong Chhnang province, obtained slightly more than 2.02 billion riels from the commune/sangkat fund in 2005, an increase of about 14.0 percent from 2004. A total of 1.38 billion riels was for development and the remaining 0.64 billion riels for administration.

**2005 Commune/Sangkat Fund Allocation to Pursat Province**




Source: Seila Task Force (January 2005), Annual Work Plan and Budget 2005

ខេត្តក្រចេះ ទទួលបានមូលនិធិរបស់ឃុំ/សង្កាត់ ១,៦៩ពាន់លានរៀលនៅឆ្នាំ២០០៥ រឺ ១៥,០%ច្រើនជាង ២០០៤ ។ ក្នុងនេះមូលនិធិសំរាប់អភិវឌ្ឍន៏មាន ១,២០ពាន់លានរៀល និងសំរាប់រដ្ឋបាល ០,៤៩ពាន់លានរៀល ។

Commune/sangkat funds allocated to Kratie province in 2005 rose by 15.0 percent to 1.69 billion riels. Development amounted to 1.20 billion riels and administration to 0.49 billion riels.

**2005 Commune/Sangkat Fund Allocation to Kratie Province**




Source: Seila Task Force (January 2005), Annual Work Plan and Budget 2005

# ការអនុវត្តន៍ថវិកាជាតិ

# National Budget Operations

នៅខែតុលា ២០០៥ ប្រតិបត្តិការថវិកាចរន្តកម្ពុជា មានអតិរេកប្រហែល ៥៩,៥ពាន់លានរៀល រឺ ១៩%ខ្ពស់ជាងខែមុន ។ ក្នុងនេះទាំងចំនូល និង ចំនាយបានថយចុះ ប៉ុន្តែចំនូលបានថយចុះយឺតជាងចំនាយ ។ អតិរេកនៅខែនេះ ធំជាងអតិរេកនៅខែតុលា ២០០៤ ចំនួនបីដង ។

In October, current budget operations recorded a surplus of around 59.5 billion riels, 19.0 percent higher than in the preceding month. Both revenue and expenditure declined, but the decrease of revenue was slower than that of expenditure. This surplus was three times higher than in October 2004.

**Current Budget Operations**
(billion riels)




*Note: Provisional for 2004 and Jan.–Oct. 2005.*
Source: Ministry of Economy and Finance

នៅខែតុលា ចំនូលថវិកាចរន្តចុះដល់ ១៧៣,៥ពាន់លានរៀល រឺចុះ ២៥,៤% ធៀបនឹងខែកញ្ញា (ប៉ុន្តែកើន ៣៧,២%ធៀបនឹងខែតុលាឆ្នាំមុន) ។ ក្នុងនេះ ពន្ធក្នុងស្រុកថយចុះ ១៤% ដល់ ៤០,៤ពាន់លាន (ពន្ធលើប្រាក់ចំនេញ និង VAT ធ្លាក់ចុះ), ចំនូលមិនមែនពន្ធថយចុះ ៦៣,៣% ដល់ ៣២,៨ពាន់លាន ប៉ុន្តែចំនូលពន្ធនាំចូល-នាំចេញ កើន ៤,៤% ដល់ ១០០,៣ពាន់លាន ។

Current budget revenue in October declined by 25.4 percent to 173.5 billion riels compared to September. This reflected a decline in revenue from domestic tax by 14 percent to 40.4 billion riels and non-tax sources by 63.3 percent to 32.8 billion riels. There was, however, an increase of 4.4 percent to 100.3 billion riels in revenue from import and export taxes. The decrease in domestic tax was mainly due to a drop in profit tax and domestic VAT. Likewise, revenue from non-tax sources declined because of a decrease in revenue from forest exploitation, tourism, civil aviation and visa fees. However, total current revenue was up by 37.2 percent from October 2004.

**Current Budget Revenue**
(billion riels)




*Note: Provisional for 2004 and Jan.–Oct. 2005.*
Source: Ministry of Economy and Finance

ពីខែកញ្ញា ដល់ តុលា ចំនាយថវិកាចរន្តថយចុះ ៣៧,៥% ដល់ ១១៤,0 ពាន់លានរៀល ដោយខ្ទង់ចំនាយធំៗទាំង៥ បានថយចុះទាំងអស់ គឺ ចំនាយលើការពារជាតិនិងសន្តិសុខថយចុះ ២១,៧%, ចំនាយរដ្ឋបាលសេដ្ឋកិច្ចចុះ ២៤,៣%, ចំណាយរដ្ឋបាលសង្គមកិច្ចថយចុះ ២៤,៣%, ចំនាយរដ្ឋបាលទូទៅចុះ ៤៩,៨% និង ចំនាយផ្សេងទៀតចុះ ៥៦,៥% ។ ធៀបនឹងខែតុលា ២០០៤ ចំនាយចរន្តសរុបកើនប្រហែល ៧% ។

Current budget expenditure also declined, by 37.5 percent to about 114.0 billion riels, from September to October. The five main items of current budget expenditure all declined during this period. Expenditure on defence and security dropped by 21.7 percent, on economic administration by 24.3 percent, on social administration by 40.8 percent, on general administration by 49.8 percent and on other by 56.5 percent. Compared to October 2004, total current spending was up by about 7 percent.

**Current Budget Expenditure**
(billion riels)




*Note: Provisional for 2004 and Jan.–Oct. 2005.*
Source: Ministry of Economy and Finance

# សកម្មភាពសេដ្ឋកិច្ចនៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា

# Economic Activity of Selected Economic Partners of Cambodia

នៅខែវិច្ឆិកា ទំនិញនាំចេញរបស់ US និងតំបន់អឺរ៉ូ កើនឡើង ប៉ុន្តែទំនិញនាំចេញរបស់ជប៉ុនថយចុះ ។ ទំនិញនាំចេញUS កើនដល់ ៧៧,៣៦ពាន់លានដុល្លារ រឺកើន ៣%ធៀបនឹងខែមុន ដោយភាគច្រើនជាកំនើនទំនិញមូលធន ទំនិញប្រើប្រាស់ និងសំភារៈខាងឧស្សាហកម្ម ។ ទំនិញនាំចេញរបស់តំបន់អឺរ៉ូ កើន ១% ដល់ ១២៧,៨៨ពាន់លានដុល្លារ និងរបស់ជប៉ុនថយចុះដល់ ៥០,៦៩ពាន់លានដុល្លារ (៥២,១៦ពាន់លានដុល្លារនៅខែតុលា) ។

In November, US and Eurozone goods exports increased, while goods exports from Japan decreased. US exports rose by 3 percent from the previous month, from $75.2 billion to $77.36 billion. The increase was mostly accounted for by increases in capital goods, consumer goods and industrial supplies and materials. Eurozone goods exports rose by 1 percent from the previous month, from $126.76 billion1 to $127.88 billion. Japan's goods exports in November declined to $50.69 billion, down from $52.16 billion in October.

**Goods Exports by the US, Eurozone and Japan**
(US$ billion)




Sources: BEA, Eurostat and OECD

នៅខែវិច្ឆិកា ទំនិញនាំចេញរបស់កូរ៉េខាងត្បូងកើនដល់ ២៥,៨៩ពាន់លានដុល្លារ រឺកើន ២%ធៀបនឹងខែមុន ។ ក្នុងខែវិច្ឆិកានេះដែរ ការនាំចេញរបស់តៃវ៉ាន់ថយចុះ ៤% ដល់ ១៧,១៧ពាន់លានដុល្លារ ក្នុងនេះ ផលិតផលកសិកម្ម និងផលិតផលឧស្សាហកម្ម បានថយចុះ ប៉ុន្តែផលិតផលកសិកម្មកែច្នៃបានកើនឡើង បើធៀបនឹងខែមុន ។

Goods exports from South Korea increased in November, while goods exports from Taiwan decreased. South Korea's exports of goods rose by 2 percent from the previous month to $25.89 billion. Except for crude materials and manufacturing goods, all categories of exports grew from the previous month. Taiwan's exports in November registered a 4 percent decrease from the previous month to $17.17 billion. Agricultural products, heavy and non-heavy industrial products declined, while processed agricultural products increased compared to the previous month.

**Goods Exports by South Korea and Taiwan**
(US$ billion)




Sources: National statistics departments of respective countries

នៅខែវិច្ឆិកា ២០០៥ ម៉ាឡេស៊ីមានអតិរេកពាណិជ្ជកម្ម ២,២៩ពាន់លានដុល្លារ (២,៧៧ពាន់លាននៅខែតុលា) ក្នុងនេះការនាំចូលសរុបថយចុះ ២០% ដល់ ៩,១៦ពាន់លាន រីឯការនាំចេញថយចុះ ២១% ដល់ ១០,៣២ ពាន់លាន (គឺថយចុះ ផលិតផលអគ្គីសនីនិងអេឡិចត្រូនិក, ផលិតផលគីមី, ប្រេងឆៅ, ប្រេងឆា, បរិក្ខារប្រើប្រាស់, គ្រឿងបន្លាស់ និងផលិតផលជាលោហៈ) ។

In November 2005, Malaysia recorded a trade surplus of $2.29 billion, compared to $2.77 billion in October. Total exports in November declined by 21 percent to $10.32 billion, while total imports decreased by 20 percent to $9.16 billion. Exports of electrical and electronic products, chemicals and chemical products, crude petroleum, palm oil, optical and scientific equipment, machinery, appliances and parts and metal manufactures declined.

**Malaysia's External Trade**
(US$ billion)




Source: National Statistics Department of Malaysia

1. Export figures in previous issues were quoted from different sources and found greater differences.

# ស្ថានភាពអតិផរណានៃបណ្ដាប្រទេសជាដៃគូរបស់កម្ពុជា

# Inflation Rates in Selected Economic Partners of Cambodia

ក្នុងរយៈ១ឆ្នាំដល់ចុងខែវិច្ឆិកា អត្រាអតិផរណាទូទៅនៅជប៉ុនធ្លាក់ចុះ ០,៨% ប៉ុន្តែអតិផរណាលើទំនិញស្នូលដែលគេប្រើជារង្វាស់និន្នាការថ្លៃ បានកើនឡើងតាមអត្រាប្រចាំឆ្នាំ ០,១% ដែលនាំឱ្យគេរំពឹងថា ធនាគារជាតិជប៉ុន នឹងបោះបង់គោលនយោបាលហិរញ្ញវត្ថុធូរទូលាយបំផុតនេះ ក្នុងពេលដ៏ឆាប់។ នៅពេលដូចគ្នា អតិផរណាទំនិញប្រើប្រាស់ ថយចុះ ៣,៥% នៅ US និង ថយចុះ ២,៤% នៅសហភាពអឺរ៉ុប ។

The Japanese overall rate of inflation fell by 0.8 percent in the year to November. However, core inflation which is used as a primary measure of price trends, edged up at an annual rate of 0.1 percent, spurring expectations that the Bank of Japan may soon abandon its ultra-loose monetary policy. During the same period, consumer inflation eased to 3.5 percent in the US and edged down to 2.4 percent in the EU.

**Inflation in the US, Europe and Japan**

(percentage change of prices over previous year)




*Note: The latest data available are for November 2005.*
Sources: IMF and the *Economist* (7–13 January 2006)

នៅខែវិច្ឆិកា ថ្លៃទំនិញប្រើប្រាស់នៅហុងកុង កើន ១,៧% ។ ថ្លៃទំនិញប្រើប្រាស់មានអត្រាកំនើនប្រចាំឆ្នាំនៅខែវិច្ឆិកា ទាបជាងខែតុ ដោយសារជាសំខាន់ កំនើនថ្លៃម្ហូបអាហារជាមូលដ្ឋានខ្លះ ថ្លៃគ្រឿងអលង្ការ ព្រមទាំងថ្លៃខ្សែទស្សនកិច្ច ។ ក្នុងកំឡុងពេលដដែល អតិផរណាទំនិញប្រើប្រាស់កើន ១,៣% នៅចិន ប៉ុន្តែថយចុះ ២,៤% នៅកូរ៉េខាងត្បូង។

Hong Kong year-on-year prices increased by 1.7 percent in November. The smaller year-on-year increase in the composite CPI in November than in October was mainly attributable to moderated increases in prices of some basic foodstuffs and jewellery as well as the charges for package tours. During the same period, consumer inflation edged up to 1.3 percent in China but decelerated to 2.4 percent in South Korea.

**Inflation in China, Hong Kong and South Korea**

(percentage change of prices over previous year)




*Note: The latest data available are for November 2005.*
Sources: IMF and the *Economist* (7–13 January 2006)

នៅសិង្ហបុរី សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើន ១,០% នៅខែវិច្ឆិកា បើធៀបនឹងខែដូចគ្នាឆ្នាំ២០០៤ ។ តាមនាយកដ្ឋានស្ថិតិរបស់សិង្ហបុរី រឿងនេះបង្ហាញជាសំខាន់អំពី ការឡើងថ្លៃម្ហូបអាហារ សំលៀកបំពាក់ ស្បែកជើង ការអប់រំ សំភារៈការិយាល័យ ឈ្នួលផ្ទះ ការថែទាំសុខភាព និងលំហែកំសាន្ត ។ នៅពេលនេះដែរ អត្រាអតិផរណាទំនិញប្រើប្រាស់ប្រចាំឆ្នាំ គឺ ៣,៥%នៅម៉ាឡេស៊ី និង ៥,៩%នៅថៃ ។

The Singapore's consumer price index rose by 1.0 percent in November 2005 compared to the same month a year earlier. According to the Department of Statistics of Singapore, this largely reflected more costly food, clothing and footwear, education and stationery, housing, health care and recreation. At the same time, the annual rate of consumer inflation was 3.5 percent in Malaysia and 5.9 percent in Thailand.

**Inflation Rate in Selected ASEAN Countries**

(percentage change of prices over previous year)




*Note: The latest data available are for November 2005.*
Sources: IMF and the *Economist* (7–13 January 2006)

# អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ

# Exchange Rates in World Markets

នៅខែមករា ដុល្លារUSបន្តចុះថ្លៃទល់នឹងរូបិយវត្ថុចំបងៗដោយ ១ដុល្លារUS ប្តូរបាន០,៨៣អឺរ៉ូ រឺចុះថ្លៃ១,៨%ធៀបនឹងខែមុន។ ម្យ៉ាងទៀត ១ដុល្លារUS ប្តូរបាន ១១៥,២យ៉េន ធៀបនឹង ១១៨,៣៧យ៉េននៅខែមុន ។ ដុល្លារUS បានចុះថ្លៃក្រោយមានសញ្ញាបង្ហាញថា អតិផរណាបានកើនឡើងនៅអឺរ៉ុប និងជប៉ុន បន្ទាប់សន្ទស្សន៍ហ៊ុននៅ US បានចុះថ្លៃយ៉ាងខ្លាំង ។

In January, the US dollar continued to lose ground against most major currencies. It traded at €0.83, a 1.8 percent depreciation from the previous month. The dollar bought ¥115.2, down from ¥118.37 a month earlier. The dollar dropped after there were signals that inflation was rising in Europe and Japan and following a sharp decline in US stocks.

## Euro and Japanese Yen against US Dollar




*Note: Data are up to 26 January 2006*
Source: Federal Reserve Bank of New York

នៅខែមករា ប្រាក់វ៉ុនកូរ៉េខាងត្បូងឡើងថ្លៃយ៉ាងខ្លាំងទល់នឹង ដុល្លារUS ដោយ ១ដុល្លារUS ប្តូរបានតែ ៩៨៨,៣៣វ៉ុន ធៀបនឹង ១.០២១,៩៨វ៉ុន នៅខែមុន ។ វ៉ុនបានឡើងថ្លៃដោយសារមានការនាំចេញច្រើន និងការរំពឹងថា ធនាគារកណ្តាលUS នឹងបញ្ចប់ការតំលើងការប្រាក់ក្នុងពេលដ៏ឆាប់ដែលធ្វើឱ្យដុល្លារUSលែងសូវមានកំលាំងទាក់ទាញទៀត។ ក្នុងរយៈពេលដដែល ដុល្លារហុងកុងនៅនឹងទល់នឹងដុល្លារUS ដោយប្តូរបាន ៧,៧៥ដុល្លារហុងកុង /ដុល្លារUS ។

The South Korean won appreciated sharply against the US dollar in January, trading at 988.33 compared to 1021.98 a month earlier. The won was strengthened by robust exports and the expectation that the US Federal Reserve would soon end its rate hike policy, which would make the US currency less attractive. During the same period, the Hong Kong dollar was flat against its US counterpart, trading at HK$ 7.75 per US dollar.

## South Korean Won and Hong Kong Dollar against US Dollar




*Note: Data are up to 26 Jan. 2006*
Source: Federal Reserve Bank of New York

នៅខែមករា ដុល្លារសិង្ហបុរីឡើងថ្លៃទល់នឹង ដុល្លារUS ដោយ ១ដុល្លារUS ប្តូរបានតែ ១,៦៣៥ដុល្លារសិង្ហបុរី ធៀបនឹង ១,៦៧៣ដុល្លារសិង្ហបុរី នៅខែធ្នូ ។ ក្នុងពេលជាមួយគ្នា ប្រាក់បាតថៃប្តូរបាន ៣៩,៧៨បាត/ដុល្លារUS រឺឡើងថ្លៃ ៣%ធៀបនឹងខែមុន។ ការចុះថ្លៃដុល្លារUS ទល់នឹងរូបិយវត្ថុអាស៊ី ធ្វើឱ្យធនាគារកណ្តាលនានាក្នុងតំបន់ ធ្វើអន្តរាគមន៍ចូលទីផ្សារដើម្បីទប់ទល់ការជួញដូរបែបឆក់ឱកាស និងពន្យឺតការចុះថ្លៃដុល្លារUS ។

In January, the Singapore dollar advanced against the greenback, to 1.635 from 1.673 in December. Meanwhile, the Thai baht traded at 39.78 baht/USD, a 3 percent appreciation from a month earlier. The depreciation of the US dollar against Asian currencies has led a number of central banks in the region to step into the market to smooth volatile trading and slow the dollar's fall.

## Thai Baht and Singaporean Dollar against US Dollar




*Note: Data are up to 26 January 2006*
Source: Federal Reserve Bank of New York

# ស្ថានភាពតំលៃទំនិញលើទីផ្សារអន្តរជាតិ

# Commodity Prices in World Markets

នៅខែធ្នូ ថ្លៃអង្ករពិភពលោកនៅថេរ ដោយសារសកម្មភាពមិនសូវមមាញឹក នៅទីផ្សារនាពេលឈប់សំរាកចុងឆ្នាំ ។ សន្ទស្សន៍ថ្លៃអន្តរជាតិ នៅនឹងត្រឹម ១១៦,៤ពិន្ទុ។ ថ្លៃអង្ករនៅUS នៅថេរត្រឹម ៣០៣ដុល្លារ/តោន ។ នៅថៃ ថ្លៃអង្ករក៏នៅថេរដែរនៅលើទីផ្សារ ដោយសារមានអ្នកទិញចំនួលថ្មីតិចតួច ប៉ុណ្ណោះ ។ អង្ករ ថៃ 100%B លក់បាន ២៨៤ដុល្លារ/តោន ធៀបនឹង ២៨២ដុល្លារ នៅខែ វិច្ឆិកា។

In December, world rice prices remained steady due to market slowdowns near the end-of-year holidays. The international prices index (IPO) was constant at 116.4 points. Rice prices in the US held steady at $303 per ton. In Thailand, prices also kept steady in a restrained market with few new buyers. Thai 100 percent B was at $284 per ton, up from $282 in November.

**International Prices Index and Export Rice Prices**
($/ton FOB)




Sources: Osiriz/InfoArroz and InterRice

នៅខែមករា ថ្លៃសណ្តែកសៀងធ្លាក់ចុះ ប៉ុន្តែថ្លៃពោតនៅថេរ ។ សណ្តែកសៀង លក់បាន ២៣៣,៣៣ ដុល្លារ/តោន រឺចុះថ្លៃ ២,៥%ធៀបនឹងខែធ្នូ (២៣៩,៤៧ដុល្លារ/តោន) ប៉ុន្តែឡើងថ្លៃ ៦% ធៀបនឹងខែមករា ២០០៥។ ថ្លៃពោតនៅថេរត្រឹម ១០២,៧១ដុល្លារ/តោន នៅខែមករា ។ នៅខែធ្នូ ប្រេងឆាលក់បាន ៤២៩ដុល្លារ/តោន គឺចុះពី ៤៤៤ដុល្លារ នៅខែវិច្ឆិកា។

The price of soybeans declined slightly in January, while the price of maize remained steady. Soybeans sold at $233.33 per ton, down from $239.47 per ton in December—a 2.5 percent decrease, but a 6 percent increase over January 2005. The price of maize was steady at $102.71 per ton in January. In December, palm oil sold at $429 per ton, down from $444 in November.

**International Prices of Soybean, Maize and Palm Oil** ($/ton FOB)




Source: Food and Agriculture Organisation (FAO)

នៅខែមករា ប្រេងឆៅ និងសាំងបានឡើងថ្លៃ ។ ថ្លៃប្រេងឆៅលក់ដល់ដៃ នៅខែមករានៃប្រទេសសមាជិក OPEC គឺ ៥៧,៨០ដុល្លារ/ធុង រឺកើន ១០% ធៀបនឹងខែមុន។ សាំងធម្មតានៅ US Gulf Coast ឡើងថ្លៃដល់ ៤៥,២៩ សេន/លីត្រ នៅខែមករា រឺឡើងថ្លៃ ១០% ធៀបនឹងខែធ្នូ (៤១,២៨សេន /លីត្រ) ។

In January, the prices of crude oil and gasoline increased. The OPEC countries spot price of crude oil was $57.80 per barrel, a 10 percent increase from the previous month. Regular gasoline in the US Gulf Coast in January rose by 10 percent from the previous month, selling at 45.29 cents per litre against 41.28 cents in December.

**Prices of Crude Oil and Gasoline**




***Note: Data are up to 25 January** 2006*
Source: US Energy Information Administration

## ព័ត៌មានសេដ្ឋកិច្ច /Economic News

**កម្ពុជាចាប់ផ្តើមកសាងរោងចក្រស៊ីម៉ង់ត៍:** រោងចក្រស៊ីម៉ង់ត៍កំពត ដែលជារោងចក្រស៊ីម៉ង់ត៍ដ៏ធំនៅកម្ពុជា បានចាប់ផ្តើមដំណើរការសាងសង់ បន្ទាប់ពីធ្វើពិធីបើកការដ្ឋាន ដោយមានការចូលរួមជាអធិបតីរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅស្រុកបន្ទាយមាស ខេត្តកំពត ប្រហែល ១៤៣គ.ម នៅភាគនិរតីក្រុងភ្នំពេញ ។ ផលិតកម្មស៊ីម៉ង់ត៍តាមស្តង់ដារខ្ពស់ នឹងចាប់ផ្តើមក្រោយពេលរោងចក្របានសាងសង់រួចរាល់ឆ្នាំក្រោយ ។ សមត្ថភាពផលិតមានទំហំប៉ាន់ស្មាន ៩០០.០០០តោន/ឆ្នាំ ដើម្បីបំពេញតំរូវការក្នុងស្រុក និងកាត់បន្ថយតំរូវការនាំចូល ។ រោងចក្រនេះជាវិនិយោគចំរុះរវាងក្រុមហ៊ុន Siam Cement របស់ថៃ និងក្រុមហ៊ុន ខូវ ជូលី MKK ហើយនឹងប្រើកម្មករដល់ ៤០០នាក់ ។ កម្ពុជាបានចំនាយប្រហែល ១០៥ដុល្លារនាំចូលស៊ីម៉ង់ត៍នៅឆ្នាំ២០០៤ និង ១៤០ដុល្លារនៅ ២០០៥។ នៅឆ្នាំ២០០៨ ស៊ីម៉ង់ត៍ផលិតបាននឹងចេញលក់ជំនួសឱ្យស៊ីម៉ង់ត៍នាំចូល ។

**វេទិកាសេដ្ឋកិច្ចកម្ពុជាដើម្បីជួយដល់សេដ្ឋកិច្ចកម្ពុជា:** នៅថ្ងៃ១៧ មករា វេទិកាសេដ្ឋកិច្ចកម្ពុជាបានបើកដំណើរការ ដើម្បីវិភាគពីចំនុចខ្លាំង ចំនុចខ្សោយ ឱកាស និងការគំរាមកំហែង (ការវិភាគ SWOT) ដល់សេដ្ឋកិច្ច និងសង្គម ។ ការវិភាគបានបង្ហាញថា ឱកាសធំបំផុតសំរាប់កម្ពុជា គឺចំនូលបានពីធនធានប្រេងកាត និងឧស្ម័នធម្មជាតិ ប៉ុន្តែការប្រើប្រាស់ចំនូលមិនត្រឹមត្រូវក៏អាចកើតមាន និងបង្កគ្រោះថ្នាក់ធំដែរ ។ អត្តសញ្ញាណជាតិ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងសកលភាវូបនីយកម្មជាមួយ ប្រទេសជិតខាង គឺជាចំនុចខ្លាំងរបស់កម្ពុជា។ ប៉ុន្តែក៏មានចំនុចខ្សោយខ្លះ ដូចជា ភាពក្រីក្រនៅមានកំរិតខ្ពស់ ថាមពលថ្លៃខ្ពស់ សេដ្ឋកិច្ចមានចំនាយខ្ពស់និងគ្មានលក្ខណៈប្រកួតប្រជែង និងរចនាសម្ព័ន្ធរដ្ឋមានបុគ្គលិកច្រើនពេក ជាដើម។

**កិច្ចព្រមព្រៀងពាណិជ្ជកម្មរវាងកូរ៉េខាងត្បូង និងសិង្ហបុរី នឹងចាប់អនុវត្តនៅខែមីនា:** យោងតាមក្រសួងការបរទេសនិងពាណិជ្ជកម្មកូរ៉េខាងត្បូង, កូរ៉េខាងត្បូង និងសិង្ហបុរី នឹងចាប់អនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី (FTA) នៅថ្ងៃទី២ មីនា។ កិច្ចព្រមព្រៀងតំរូវឱ្យកូរ៉េលុបពន្ធគយ ៩១,៦% លើទំនិញ ១០.៣១៥មុខ ដែលធ្វើពាណិជ្ជកម្មជាមួយសិង្ហបុរីក្នុងរយៈពេល ១០ឆ្នាំ ។ ជាការតបស្នង សិង្ហបុរីនឹងលុបពន្ធគយលើគ្រប់មុខទំនិញដែលធ្វើពាណិជ្ជកម្មជាមួយកូរ៉េខាងត្បូង នៅពេលកិច្ចព្រមព្រៀងចូលជាធរមាន ។ លើសពីនេះ នៅអនាគត សិង្ហបុរីនឹងអនុវត្តអត្រាពន្ធអនុគ្រោះចំពោះផលិតផលរបស់រោងចក្រ Kaesong នៅកូរ៉េខាងជើង ។ FTA ខាងលើនឹងជួយក្រុមហ៊ុនកូរ៉េខាងត្បូង ឱ្យចូលទីផ្សារអាស៊ីអាគ្នេយ៍ និងជំរុញពាណិជ្ជកម្មជាមួយសិង្ហបុរី។ កន្លងមក កូរ៉េខាងត្បូងបានចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយ ស៊ីលី សិង្ហបុរី និងសមាគមពាណិជ្ជកម្មសេរីនៅអឺរ៉ុប ដែលរួមមាន អ៊ីស្លង់ Liechtenstein ន័រវ៉េ និងស្វីស ។

***Cambodia starts building largest cement factory:*** Cambodia's Kampot Cement factory, the largest cement producer in the country, started construction with Prime Minister Hun Sen presiding over the ground-breaking ceremony in Banteay Meas district, Kampot province, about 143 km southwest of Phnom Penh. High standard cement production will begin when the factory construction is finished by the end of next year. Its annual production capacity is estimated at 900,000 tons of cement to serve domestic demand and lower dependence on imports. A $300 million joint venture between Thailand's Siam Cement and the local company Khaou Chully MKK Co., the factory will employ up to 400 workers. The country spent around $105 million to import cement in 2004 and $140 million in 2005. By 2008, locally produced cement will be sold in the market instead of imported cement. *(Cited from Xinhua 26/1/2006)*

***Cambodia Economic Forum launched to help country's economy:*** The Cambodia Economic Forum was launched on Tuesday to analyse the strengths, weaknesses, opportunities and threats (SWOT) facing the economy and society. A SWOT analysis concludes that Cambodia's greatest opportunity is the revenue that will be generated by the exploitation of the country's offshore oil and natural gas deposits. The potential for misuse of this revenue stream is Cambodia's greatest threat. Strong national identity, macro-economic stability and globalising neighbours are cited as the strengths of the country. The study also put forward some weaknesses, such as still high poverty levels, expensive energy, a high-cost, uncompetitive economy and an expensive and overstaffed state apparatus. *(Cited from Xinhua 17/1/2006)*

***South Korea-Singapore FTA to take effect in March:*** South Korea and Singapore agreed to begin implementation of a bilateral free trade agreement (FTA) on 2 March, according to the South Korean Ministry of Foreign Affairs and Trade. The accord calls for South Korea to remove tariffs on 91.6 percent of its 10,315 trade items with Singapore within 10 years. In return, Singapore will scrap tariffs on all trade items with South Korea once the deal becomes effective. Moreover, Singapore agreed to grant preferential tariffs to products produced at Kaesong Industrial Complex in the Democratic People's Republic of Korea (DPRK) in the future. The South Korea-Singapore FTA will help South Korean companies to exploit the south-east Asian market and enhance trade with Singapore. South Korea has signed free trade deals with Chile, Singapore and the European Free Trade Association, comprising Iceland, Liechtenstein, Norway and Switzerland. *(Cited from Xinhua 31/1/2006)*